ព្រះរាជក្រម

នស/រកម/១១១៧/០១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

រដ្ឋសភា
ចូល
លេខ ៣៣៥០
ថ្ងៃទី.../១១ ឆ្នាំ២០១៧ ម៉ោង...
បញ្ជូនទៅ...

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីជលផល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា ៦ មាត្រា ៤១ មាត្រា ៤២ មាត្រា ៤៣ និងមាត្រា ៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម /០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្ដីពី

## វិសោធនកម្មមាត្រា ៦ មាត្រា ៤១ មាត្រា ៤២ មាត្រា ៤៣ និងមាត្រា ៩៥ នៃច្បាប់ស្ដីពីជលផល ដែលត្រូវប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ២០០៦

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ ..**

មាត្រា ៦ មាត្រា ៤១ មាត្រា ៤២ មាត្រា ៤៣ និងមាត្រា ៩៥ នៃច្បាប់ស្តីពីជលផល ដែលត្រូវប្រកាស ឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

**មាត្រា៦ .. ថ្មី**

រដ្ឋបាលជលផល គឺជាអាជ្ញាធររដ្ឋបាលដែលចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចគ្រប់គ្រងជលផល និងធនធានជលផល ស្របតាមគោលនយោបាយវិស័យជលផលជាតិ និងខ្លឹមសារនៃច្បាប់នេះ ។ រដ្ឋបាលជលផលមានរចនាសម្ព័ន្ធគ្រប់គ្រងដែលបែងចែកជាថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត ។ ថ្នាក់រាជធានី ស្ថិតនៅចំណុះមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្ត ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពរបស់រដ្ឋបាលជលផលត្រូវបានកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៤១ .. ថ្មី**

ហាមឃាត់ការធ្វើនេសាទ ៖

១- ជាលក្ខណៈសិប្បកម្ម ឬឧស្សាហកម្មនៅរដូវបិទនេសាទ ។

២- ជាលក្ខណៈឧស្សាហកម្មនៅក្នុងកន្លែងនេសាទបម្រុង ។

៣- នៅរដូវបើកនេសាទ ដោយប្រើឧបករណ៍គ្រប់ប្រភេទ រួមផ្សំដោយរបាំងព្រួល ឬលួសសំណាញ់មានបណ្តោយលើសពី ៥០ (ហាសិប) ម៉ែត្រ ឬលាតសន្ធឹងលើសពី ២/៣ (ពីរភាគបី) នៃទទឹងមុខទឹក អូរ ព្រែក ស្ទឹង ឬធ្វើឲ្យរាំងស្ទះផ្លូវជលយានគ្រប់ប្រភេទ ។

៤- រាល់ការប្រើសាច់មង អួន ឬលួសសំណាញ់ដែលមានក្រឡាតូចជាង ៣ (បី) សង់ទីម៉ែត្រ ធ្វើជារបាំងព្រួល ។

៥- ការប្រើឧបករណ៍ដាយចាប់ត្រី ឬដាយចាប់បង្កងខុសទីតាំងកំណត់របស់ឡូត៍ ដាយចាប់ត្រី ឬដាយបង្កង ។

**មាត្រា៤២ .. ថ្មី**

ការធ្វើនេសាទនៅក្នុងកន្លែងនេសាទបម្រុងដោយប្រើឧបករណ៍លបណ ឬរ៉ាវ ឬលបឡុក នៅក្នុងបឹងទន្លេសាបអាចអនុញ្ញាតឲ្យធ្វើបានពីថ្ងៃទី ១ ខែ កុម្ភៈ ដល់ថ្ងៃទី ២០ ខែ ឧសភា ។ ការបោះទីតាំងលបណ ឬរ៉ាវ ឬលបឡុក មិនត្រូវធ្វើឲ្យរាំងស្ទះផ្លូវជលយានគ្រប់ប្រភេទឡើយ ។ ទីតាំងលបណ ឬរ៉ាវ ឬលបឡុកទាំងឡាយ ត្រូវដកចេញឲ្យអស់មុនថ្ងៃទី ៣១ ខែឧសភា ជាដាច់ខាត ។

ចំពោះប្រវែង ទំហំនៃឧបករណ៍នេសាទ និងទីតាំងដែលត្រូវបានអនុញ្ញាតឲ្យធ្វើនេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា៤៣ .. ថ្មី**

ការធ្វើនេសាទជាលក្ខណៈសិប្បកម្មដោយអួន ទោះជាមួយវង់ ឬច្រើនវង់តភ្ជាប់គ្នាក៏ដោយអាចប្រព្រឹត្តទៅបានលុះត្រាតែអួននោះមានបណ្តោយតិចជាង ៖

៣០០ (បីរយ) ម៉ែត្រ ចំពោះកន្លែងនេសាទបម្រុងនៅក្រៅបឹងទន្លេសាប

- ៦០០(ប្រាំមួយរយ)ម៉ែត្រ ចំពោះកន្លែងនេសាទបម្រុងនៅក្នុងបឹងទន្លេសាប ។

មិនអនុញ្ញាតឲ្យធ្វើនេសាទជាលក្ខណៈសិប្បកម្មដោយអួននៅក្នុងកន្លែងនេសាទដែលទុកសម្រាប់តែប្រជាពលរដ្ឋ នៅក្នុងកន្លែងនេសាទដែលធ្វើឲ្យរំខានដល់ការធ្វើអាជីវកម្មឡូត៍នេសាទ និងនៅក្នុងកន្លែងនេសាទដែលមានទម្លាប់ធ្វើអាជីវកម្មនេសាទដោយប្រើឧបករណ៍តូចៗ ។

ចំពោះប្រវែងជាក់ស្តែងនៃឧបករណ៍អួននិងកន្លែងនេសាទ សម្រាប់ការធ្វើនេសាទជាលក្ខណៈសិប្បកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា៩៥ .. ថ្មី**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផល ជាប្រាក់សមាមាត្រទៅនឹងថ្លៃឈ្នួលនេសាទ ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឲ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម ៖

១- ផ្ទេរលិខិតអនុញ្ញាតឲ្យធ្វើអាជីវកម្មនេសាទដោយគ្មានការអនុញ្ញាត ។

២- ប្រើប្រាស់នាវានេសាទគ្មានលិខិតអនុញ្ញាត រៀបចំឧបករណ៍នេសាទដែលមានលក្ខណៈត្រៀមធ្វើនេសាទក្នុងដែននេសាទសមុទ្រ ។

៣- ប្រើប្រាស់នាវានេសាទធ្វើនេសាទក្នុងដែននេសាទគ្មានលិខិតអនុញ្ញាត ឬគ្មានសៀវភៅនាវានេសាទ ។

៤- ប្រើប្រាស់នាវានេសាទមានឧបករណ៍អួនអូសដោយកម្លាំងម៉ាស៊ីននៅក្នុងកន្លែងនេសាទតាមឆ្នេរដោយការរៀបចំមានលក្ខណៈត្រៀមធ្វើនេសាទ ។

៥- ប្រើប្រាស់ទូក កាណូត កប៉ាល់នេសាទដោយគ្មានចុះបញ្ជីពីរដ្ឋបាលជលផល ។

៦- មិនអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅនាវានេសាទ ។

៧- នេសាទដោយលបណ ឬរ៉ាវ ឬលបឡុកក្នុងតំបន់កំណត់ហួសសុពលភាពនៃការអនុញ្ញាត។

៨- នេសាទជាលក្ខណៈសិប្បកម្មដោយអួនលើសពី ៣០០ (បីរយ) ម៉ែត្រនៅក្រៅបឹងទន្លេសាប និងលើសពី ៦០០ (ប្រាំមួយរយ)ម៉ែត្រនៅក្នុងបឹងទន្លេសាប និងខុសពីប្រវែងជាក់ស្តែងនៃឧបករណ៍អួន និងកន្លែងនេសាទសម្រាប់ការធ្វើនេសាទជាលក្ខណៈសិប្បកម្ម ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៩- នេសាទជាលក្ខណៈសិប្បកម្មដោយអួននៅក្នុងកន្លែងនេសាទដែលទុកសម្រាប់តែប្រជាពលរដ្ឋ នៅក្នុងកន្លែងដែលធ្វើឲ្យរំខានដល់ការធ្វើអាជីវកម្មក្នុងឡូត៍នេសាទ និងក្នុងកន្លែងដែលទម្លាប់ធ្វើអាជីវកម្មនេសាទដោយប្រើឧបករណ៍តូចៗ ។

១០- នេសាទជាលក្ខណៈសិប្បកម្មគ្មានលិខិតអនុញ្ញាត ខុសទីតាំងនេសាទ ខុសយថាប្រភេទឧបករណ៍នេសាទ ឬប្រើប្រាស់លិខិតអនុញ្ញាតហួសសុពលភាព ។

១១- នេសាទដោយលបណ ឬរ៉ាវ ឬលបឡុក ខុសពេលកំណត់ ខុសទីតាំងកំណត់ លើសពីប្រវែង និងទំហំដែលកំណត់ រាំងស្ទះដល់ផ្លូវជលយានគ្រប់ប្រភេទ ឬមិនដកចេញតាមពេលកំណត់ក្នុងតំបន់កំណត់ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

១២- នេសាទជាលក្ខណៈឧស្សាហកម្មដោយគ្មានលិខិតអនុញ្ញាត ឬហួសសុពលភាពនៃលិខិតអនុញ្ញាត ។

១៣- នេសាទប៉ះពាល់ ឬខូចខាតដល់ស្មៅសមុទ្រ ឬផ្កាថ្ម ។

១៤- មិនព្រមផ្អាកធ្វើនេសាទតាមការបញ្ជាប់ជាបណ្ដោះអាសន្នរបស់រដ្ឋបាលជលផលមានសមត្ថកិច្ច ។

១៥- ប្រើសាច់មង អួន ឬលួសសំណាញ់ដែលមានក្រឡាតូចជាង ៣ (បី) សង់ទីម៉ែត្រ ធ្វើរបាំង រួមផ្សំ ឬជំនួសរបាំងព្រួល ។

១៦- ធ្វើអាជីកម្មនេសាទដោយមិនអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅបន្ទុកឡូត៍នេសាទ ឬលិខិតអនុញ្ញាតឲ្យធ្វើនេសាទ ។

១៧- បោះរបាំងក្នុងឡូត៍នេសាទ ឬផ្លូវទឹកនៃតំបន់ឆ្នេរសមុទ្រដោយមិនបើកមុខទឹកឲ្យជលយានធ្វើចរាចរណ៍បាន ។

១៨- ធ្វើឲ្យចាល់ទឹកនៅមុខរបាំង ។

១៩- បោះទីតាំងឡូត៍ជាយខុសពីការកំណត់ ។

២០- ប្រើប្រាស់ឧបករណ៍នេសាទ ឬពេលវេលានេសាទនៅក្នុងកន្លែងនេសាទសហគមន៍ខុសពីការកំណត់របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះចាប់ពី ២ (ពីរ) ដង ឡើងទៅ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ដែលត្រូវពិន័យអន្តរការណ៍ក្នុងមាត្រានេះ និងវត្ថុតាងពិតប្រាកដទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រាពីរ ..**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០១៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស/រកម/១១១៧/០៤៥

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**ហត្ថលេខា**
**វេង សាខុន**

**លេខ:១០៦៦ស.ណ**
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**